# ច្បាប់ទីលំនៅស្មើភាពគ្នានិងជាតិកំណើតដើម

## Fair Housing and National Origin

ច្បាប់សហព័ន្ធនិងច្បាប់រដ្ឋ ហាមឃាត់ការប្រកាន់លក្ខណៈនៅក្នុងកិច្ចការខាងទីលំនៅដោយព្រោះតែជាតិកំណើតដើម ។

**តើកិច្ចការពារ "ជាតិកំណើតដើម "មានន័យថាដូចម្តេច?**

ជាតិកំណើតដើម (national origin) របស់អ្នកគឺសំដៅទៅកន្លែងកំណើត បុព្វជន ភាសា ហើយនិង/ឬទំនៀមទំលាប់របស់អ្នក ។ គឺជារឿងខុសច្បាប់ដែលម្ចាស់ផ្ទះ បដិសេធការជួលទីលំនៅ ឬបំរើនរណាម្នាក់ខុសពីគេនៅក្នុងកិច្ចការផ្នែកទីលំនៅពីព្រោះតែ៖

- ឈ្មោះ រូបរាង សម្លេងនិយាយរបស់ជននោះ ឬការចូលរួមនៅក្នុងទំនៀមទម្លាប់ដែលជាប់ទាក់ទងនិងសញ្ជាតិមួយ ។
- ម្ចាស់ផ្ទះយល់ខុសថាជននោះចូលរួមនៅក្នុងសញ្ជាតិពិសេសណាមួយ ។
- ជននោះសេពគប់ជាមួយមនុស្សដែលមានជាតិកំណើតដើមពិសេសណាមួយ ។

ច្បាប់ទីលំនៅស្មើភាពគ្នាអនុវត្តចំពោះទីលំនៅជួល ការលក់ផ្ទះ ការឲ្យខ្ចីប្រាក់ទិញទីលំនៅ ការធានារ៉ាប់រងផ្នែកទីលំនៅ ហើយនិងការផ្សាយពាណិជ្ជកម្ម ។ គ្មាននរណាម្នាក់អាចបដិសេធទីលំនៅ កំរិតព្រំដែនផ្នែកទីលំនៅ ធ្វើឲ្យបាក់ទឹកចិត្តនរណាម្នាក់ដែលស្វែងរកផ្ទះ ឬមួយបង្កើតក្រិត្យវិន័យ ថ្លៃឈ្នួល ឬគោលការណ៍ផ្សេងទៀតពីព្រោះតែជាតិកំណើតដើមរបស់គ្រួសារមួយឡើយ ។

ឧទាហរណ៍ធម្មតាខ្លះនៃការប្រកាន់លក្ខណៈដោយយោងលើជាតិកំណើតដើម មានរួមទាំង បង្វែរអ្នកជួលដែលមានជាតិកំណើតដើមពិសេសណាមួយទៅកាន់ផ្នែកមួយនៃចំណោមអាគារល្វែង បដិសេធធ្វើការជួសជុលដល់ផ្នែកអាគារដែលរស់នៅដោយមនុស្សដែលមានជាតិកំណើតដើមពិសេសណាមួយ ឬហាមឃាត់ឬកំរិតចំនួនភ្ញៀវរបស់អ្នកជួលពីព្រោះតែជាតិកំណើតដើមរបស់អ្នកជួល ឬភ្ញៀវរបស់គាត់ ។

**តើម្ចាស់ផ្ទះអាចប្រកាន់លក្ខណៈទល់និងមនុស្សដែលមិនចេះនិយាយអង់គ្លេសឬទេ?**

ទេ ។ តែទោះជាយ៉ាងនេះក្តី គ្មានការតំរូវតាមច្បាប់ឲ្យម្ចាស់ផ្ទះផ្តល់ការបកប្រែដល់អ្នកជួលរបស់គេឡើយ ។ បើអ្នកជួលមិនចេះនិយាយអង់គ្លេសទេ វាស្រេចទៅលើអ្នកជួលដើម្បីរកនរណាម្នាក់ឲ្យជួយគាត់ដើម្បីនិយាយទាក់ទងជាមួយម្ចាស់ផ្ទះ ។ ដើម្បីឲ្យបានច្បាស់លាស់អំពីសិទ្ធិនិងការទទួលខុសត្រូវអ្វីរបស់ពួកគេ អ្នកជួលដែលមិននិយាយអង់គ្លេសច្បាស់លាស់គួររកជំនួយក្នុងការអានកិច្ចព្រមព្រៀងជួលរបស់ពួកគេ ពីសមាជិកគ្រួសារ ឬពីមិត្តភ័ក្រដែលទុកចិត្តបាន មុនពេលពួកគេចុះហត្ថលេខាលើកិច្ចព្រមព្រៀងជួលនេះ ។ វាក៏ជាការល្អដែរ ដើម្បីរៀបចំកំណត់វាយឈ្មោះនិងលេខទូរស័ព្ទរបស់អ្នកបកប្រែដើម្បីផ្តល់ឲ្យទៅម្ចាស់ផ្ទះ ។

FAIR HOUSING COUNCIL of Oregon

1020 SW Taylor Street, Suite 700, Portland, Oregon 97205-2512

ទូរស័ព្ទ៖ 503-223-8197 ឬ 1-800-424-3247 (TTY)

បណ្តាញអ៊ីនធឺណិត៖ http://www.fhco.org, សារអេឡិកត្រូនិក៖ information@fhco.org

ទូរស័ព្ទបណ្តឹងរបស់ HUD៖ 1-800-877-0246

[Cambodian]

## តើម្ចាស់ផ្ទះអាចទាររកលេខសូស្យាល់ពីអ្នកបំរុងជួលទៅលើពាក្យសុំបានឬទេ?

ការប្រើលេខសូស្យាល់ធ្វើជាភាគមួយនៃការឆែកមើលប្រវត្តិដើមរបស់អ្នកបំរុងជួលផ្ទះ ត្រូវបានគេចាត់ទុកថាការអនុវត្តផ្នែកការជួលជាធម្មតា ដរាបណាម្ចាស់ផ្ទះទាររកលេខសូស្យាល់ពីអ្នកបំរុងជួលផ្ទះទាំងអស់ ។ បើម្ចាស់ផ្ទះទាររកលេខសូស្យាល់តែចំពោះអ្នកជួលដែលមានជាតិកំណើតដើមពិសេសណាមួយ នោះនឹងបង្កើតការបំពានលើច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា ។ ជាញឹកញាប់ ម្ចាស់ផ្ទះប្រើលេខសូស្យាល់របស់ជនម្នាក់ដើម្បីឆែកមើលការជួលពីអតីតកាល ការទិញជឿ ហើយនិងប្រវត្តិឧក្រិដ្ឋ ។ បើអ្នកជួលគ្មានលេខសូស្យាល់ទេ ម្ចាស់ផ្ទះគួរទទួលយកលេខវីសាសំរាប់ធ្វើការ ឬលេខវីសារបស់សិស្ស ។ អ្នកជួលមិនគួរប្រើលេខសូស្យាល់ក្លែងក្លាយសោះឡើយ ។

## តើអ្នកជួលមានវិធីដោះស្រាយអ្វី បើសិនជាអ្នកជួលឯទៀតរុកគួនរំខានគេដោយសារតែជាតិកំណើតដើមរបស់គេ?

ម្ចាស់ផ្ទះមានការទទួលខុសត្រូវផ្លូវច្បាប់ដើម្បីការពារអ្នកជួលមិនឲ្យគេរុកគួនរំខានដោយយោងលើជាតិកំណើតដើម ។ បើអ្នកជួលម្នាក់ត្រូវគេរុកគួនរំខានដោយសារតែជាតិកំណើតដើម ហើយម្ចាស់ផ្ទះដឹងអំពីការរុកគួននេះ ម្ចាស់ផ្ទះមានការទទួលខុសត្រូវលូកដៃចូលក្នុងរឿងនេះ ។ អ្នកជួលទាំងអស់មានសិទ្ធិតាមច្បាប់ដើម្បីមានរស់នៅដោយរីករាយនឹងទីលំនៅរបស់ពួកគេ ។ ការរុកគួនរំខានដែលចេះបន្តទៅទៀត អាចត្រូវគេដាក់ទោសដោយដេញចេញពីទីលំនៅ ។

## តើច្បាប់ផ្នែកទីលំនៅស្មើភាពគ្នាអនុវត្តចំពោះតែប្រជារាស្ត្រអាមេរិកាំងទេឬ?

នរណាដែលរស់នៅក្នុងសហរដ្ឋអាមេរិក មានកិច្ចការពារដោយច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា ។ បើនរណាម្នាក់កំពុងរស់នៅក្នុងសហរដ្ឋអាមេរិក ដោយមិនស្របច្បាប់ ពួកគេនៅតែមានសិទ្ធិដាក់ពាក្យប្តឹងតាមច្បាប់ផ្នែកទីលំនៅស្មើភាពគ្នា ប៉ុន្តែអាចសំរេចយកការមិនប្តឹងបាន ពីព្រោះថាពតិមាននេះនឹងក្លាយទៅជាឯកសារសាធារណៈ ។ ជនណាមួយដែលទូរស័ព្ទទៅក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិននឹងទទួលពតិមាននិងជំនួយដោយលាក់ការ ។

## តើខ្ញុំអាចដឹងអំពីសិទ្ធិផ្នែកទីលំនៅស្មើភាពគ្នារបស់ខ្ញុំថែមទៀតដោយរបៀបណា?

ចូរទូរស័ព្ទទៅក្រុមប្រឹក្សាផ្នែកទីលំនៅស្មើភាពគ្នានៃរដ្ឋអូរិហ្គិន (FHCO) លេខ 503-223-8197 ឬ 1-800-424-3247 ។

FAIR HOUSING COUNCIL of Oregon

1020 SW Taylor Street, Suite 700, Portland, Oregon 97205-2512

ទូរស័ព្ទ៖ 503-223-8197 ឬ 1-800-424-3247 (TTY)

បណ្ដាញអ៊ិនធើណិត៖ http://www.fhco.org, សារអេឡិចត្រូនិក៖ information@fhco.org

ទូរស័ព្ទបណ្ដឹងរបស់ HUD៖ 1-800-877-0246

[Cambodian]